VP.Start

# ដំណោះស្រាយវៃឆ្លាត

## ការធ្វើទំនើបកម្មឌីជីថល លើបណ្ដាញចែកចាយថាមពលអគ្គិសនី

DRCs ...

UNIQUE

# DRC-002




info@vpstart.com / sale@vpstart.com | www.vpstart.com | 023 888 167

# DRC-002

## ឧបករណ៍វៃឆ្លាត សម្រាប់ធ្វើទំនើបកម្មលើ Load Break Switch (LBS)







## លក្ខណៈពិសេស

- បញ្ជាផ្តាច់-ភ្ជាប់ Switchgear របស់ LBSs ពីចម្ងាយ
- ទទួលបានព័ត៌មានភ្លាមៗ ពេល Switchgear ចំហរ ឬដាច់ប្រភព
- ទទួលបានព័ត៌មានអំពីភាពអសកម្មនានាដែលកើតមាននៅលើLBS
- អាចត្រួតពិនិត្យមើលស្ថានភាពរបស់ LBSs គ្រប់ពេលវេលា គ្រប់ទីកន្លែង



## តើ អ្វីជាលក្ខណៈពិសេសរបស់ DRC-002?




ពីមុន ដើម្បីផ្តាច់ ឬភ្ជាប់ចរន្តអគ្គិសនីនៅលើ Load Break Switch (LBS) ក្រុមការងារអគ្គិសនីត្រូវធ្វើដំណើរទៅកាន់ទីតាំង LBS នោះដោយផ្ទាល់។ ពួកគាត់ត្រូវធ្វើដំណើរជាច្រើនគីឡូម៉ែត្រដោយគ្រាន់តែត្រូវផ្តាច់ ឬភ្ជាប់ Switchgear របស់ LBS។

ពេលខ្លះប្រតិបត្តិការត្រូវធ្វើឡើងដោយខានមិនបានទាំងដែលមានភ្លៀងធ្លាក់ ឬខ្យល់ខ្លាំងជាដើម ដែលនេះមិនត្រឹមតែធ្វើឱ្យខាតពេលវេលាយូរក្នុងប្រតិបត្តិការផ្តាច់-ភ្ជាប់ចរន្តអគ្គិសនី និងប៉ះពាល់ដល់អ្នកប្រើប្រាស់ថាមពលប៉ុណ្ណោះទេ តែថែមទាំងប្រឈមនឹងហានិភ័យសម្រាប់ក្រុមការងារផងដែរ។

DRC-002 ជាបច្ចេកវិទ្យាទំនើប ដែលវិស្វករជំនាញនៅ VP.Start បានអភិវឌ្ឍឡើងសម្រាប់ដោះស្រាយបញ្ហាខាងលើនេះ។ ក្រុមការងារបច្ចេកទេសអគ្គិសនី អាចគ្រប់គ្រង បញ្ជាផ្តាច់-ភ្ជាប់ LBS ពីចម្ងាយបានភ្លាមៗ និងងាយស្រួល ដោយគ្រាន់តែប្រើប្រាស់ជាមួយទូរសព្ទដៃស្មាតហ្វូន ឬតាមរយៈប្រព័ន្ធគ្រប់គ្រង RPM Grid។ អ្វីដែលកាន់តែពិសេសនោះ DRC-002 មានសមត្ថភាពធ្វើទំនើបកម្ម LBS ជាង ១៣ ម៉ូដែលផ្សេងៗគ្នា។



▲ ក្រុមការងារស្រាវជ្រាវ និងអភិវឌ្ឍ



▲ ការត្រួតពិនិត្យគុណភាពផលិតផល




# តើ DRC-002 មានមុខងារពិសេសៗបែបណាខ្លះ ?

## មុខងារបញ្ជាផ្តាច់-ភ្ជាប់ពីចម្ងាយ ( Remote Control )

ក្រុមការងារអគ្គិសនីអាចបញ្ជាផ្តាច់ ឬភ្ជាប់ Switchgear LBS បានពីចម្ងាយដោយប្រើប្រាស់កម្មវិធី PLUM នៅលើទូរសព្ទដៃស្មាតហ្វូន ឬប្រើប្រាស់ជាមួយប្រព័ន្ធគ្រប់គ្រង RPM Grid។

## មុខងារផ្តល់ដំណឹង ( Alarm Notifications )

នៅពេលដែលមានការដាច់ចរន្តអគ្គិសនីពីប្រភព DRC-002 នឹងបញ្ជូនព័ត៌មានទៅកាន់ក្រុមការងារអគ្គិសនីភ្លាមៗ ដែលក្នុងនោះបង្ហាញពីប្រភេទនៃបញ្ហាដូចជា Switchgear Off ឬ Source Absence ជាដើម។

### ប្រភេទ ALARMS របស់ DRC-002



MV Absence



Switchgear Off

## មុខងារផ្តល់ដំណឹងពេលមានភាពអសកម្មកើតឡើង (Abnormal Detection)

DRC-002 ក៏ផ្តល់ព័ត៌មានអំពីភាពអសកម្មនានាដែលកើតមាននៅលើ LBS ផងដែរមានដូចជា Switchgear Maintenance, Battery Low, Gas Low, និង Door Open ជាដើម។ មុខងារនេះ ជួយឲ្យក្រុមការងារអគ្គិសនីទទួលបានព័ត៌មានមុនពេលបញ្ហាផ្សេងៗកើតឡើងដូចជាធ្វើឲ្យ LBS គាំង មិនដំណើរការ និងបញ្ហាផ្តាច់ ឬភ្ជាប់មិនបានជាដើម។

### ALARMS ពេលមានភាពអសកម្ម កើតឡើងនៅលើ LBS



Switchgear Off



MV Absence



Switchgear Maintenance

### ការទទួលបានទិន្នន័យ Real-time ( Real-Time Data Monitoring )

ជាមួយ DRC-002 ក្រុមការងារអគ្គិសនីអាចពិនិត្យមើលស្ថានភាពរបស់ LBS ភ្លាមៗ ដូចជាស្ថានភាព Switchgear កំពុងតែចំហរ ឬភ្ជាប់ (On/Off Position) ដោយប្រើប្រាស់កម្មវិធី PLUM ឬ តាមរយៈប្រព័ន្ធ RPM Grid។

### មុខងារ User Events

មុខងារនេះរក្សាទុករាល់សកម្មភាពទាំងអស់របស់ក្រុមការងារដែលបានធ្វើប្រតិបត្តិការជាមួយ LBS ដែលផ្តល់ភាពងាយស្រួលក្នុងការកំណត់សម្គាល់ពេលមានបញ្ហាណាមួយកើតឡើង។

### មុខងារផែនទី ( Map View )

ក្រុមការងារអាចមើលដឹងពីទីតាំងរបស់ LBS បានយ៉ាងងាយស្រួលតាមរយៈ Google Map ដែលក៏ងាយស្រួលកំណត់ទីតាំងរបស់ LBS នីមួយៗ។

### មុខងារគំនូរប្លង់បច្ចេកទេស ( Single Diagram )

មុខងារនេះផ្តល់ភាពងាយស្រួលដល់ក្រុមការងារអគ្គិសនីប្រើប្រាស់តាមរូបភាពគំនូរប្លង់បច្ចេកទេស ដែលងាយស្រួលក្នុងការគ្រប់គ្រង និងកំណត់ទីតាំងរបស់ LBS ពេលមានបញ្ហាកើតឡើង។

## ដើម្បីគ្រប់គ្រង DRC-002 បានតើត្រូវធ្វើដូចម្តេច ?

### លោកអ្នកអាចគ្រប់គ្រង DRC-002 ដូចខាងក្រោម៖

- ការគ្រប់គ្រងតាមប្រព័ន្ធទូរសព្ទដៃ ដោយប្រើប្រាស់កម្មវិធី PLUM
- ការគ្រប់គ្រងតាមប្រព័ន្ធ RPM Grid នៅក្នុងបន្ទប់បញ្ជា
- បញ្ជាផ្តាច់-ភ្ជាប់ ឬស្តាប់ពីស្ថានភាពបណ្តាញតាមរយៈមុខងារ Call Control។






## ចំណុចពិសេសរបស់ DRC-002 សម្រាប់អាជីវកម្មចែកចាយថាមពលអគ្គិសនី

### ការធ្វើទំនើបកម្មដោយរក្សាបរិក្ខារអគ្គិសនីដែលកំពុងតែប្រើប្រាស់ឱ្យនៅដដែល

ការធ្វើទំនើបកម្មលើ LBS មិនតម្រូវឱ្យផ្លាស់ប្តូរបរិក្ខារដែលកំពុងតែប្រើប្រាស់នោះចេញទេ គ្រាន់តែភ្ជាប់ DRC-002 ជាការស្រេច។ បច្ចេកវិទ្យាបែបថ្មីនេះ បានផ្តល់លទ្ធភាពគ្រប់គ្រាន់ ក្នុងការធ្វើទំនើបកម្មដោយចំណាយទុនវិនិយោគតិចបំផុត បើប្រៀបធៀបទៅនឹងការផ្លាស់ប្តូរថ្មីទាំងស្រុង។

### ការធ្វើទំនើបកម្មរហ័ស

ជាមួយ DRC-002 ការធ្វើទំនើបកម្មចំណាយពេលប្រហែលត្រឹម 30នាទីប៉ុណ្ណោះ គឺអាចធ្វើឱ្យ LBS ពីធម្មតាទៅជាវ៉ែឆ្លាតបានភ្លាមៗ។

### ងាយស្រួលគ្រប់គ្រង

VP.Start បានបង្កើតប្រព័ន្ធគ្រប់គ្រងដែលផ្តល់លទ្ធភាពដល់អ្នកប្រើប្រាស់ គ្រប់កម្រិតទាំងអស់។ ប្រព័ន្ធនេះបង្កើតឡើងដូចទៅនឹងកម្មវិធីទូរស័ព្ទ ឬកុំព្យូទ័រទូទៅ ដែលគ្រាន់តែចុចពីរ ទៅបីឃ្លីក គឺអាចទទួលបានព័ត៌មានពីបណ្តាញចែកចាយ ឬបញ្ជាផ្តាច់-ភ្ជាប់ Switchgear របស់ LBS បានភ្លាមៗតែម្តង។





## ផ្តល់ផលចំណេញបន្ទាប់ពីការវិនិយោគ (Rapid Return on Investment)

- ការទទួលបានព័ត៌មានអំពីបញ្ហាផ្សេងៗនៅលើបណ្តាញចែកចាយ ក៏ដូចជាបញ្ហានៅលើ Switchgear របស់ LBS ភ្លាមៗ។
- ការទទួលបានទិន្នន័យពី LBS ដែលអាចដឹងពីស្ថានភាពជាក់ស្តែង។
- ការបញ្ជាផ្តាច់ ឬភ្ជាប់ចរន្តអគ្គិសនីពីចម្ងាយដែលបានកាត់បន្ថយការចំណាយថ្លៃប្រតិបត្តិការចុះទៅដោយផ្ទាល់។

ទាំងអស់នេះ មិនត្រឹមតែជួយឱ្យគុណភាពនៃការគ្រប់គ្រងមានភាពប្រសើរឡើង និងជួយឱ្យបណ្តាញចែកចាយមានភាពរឹងមាំ និងមានស្ថិរភាពប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងផ្តល់ផលចំណេញត្រឡប់មកវិញលឿនដល់អាជីវកម្មចែកចាយថាមពលអគ្គិសនីផងដែរ។

## ដំណើរការរបស់ប្រព័ន្ធ (System Architecture)



VP.Start

**VP.Start HQ**

Address: #15, Street 604, Sangkat Boeung Kok 2, Khan Toul Kork, Phnom Penh, Cambodia.

**VP.Start Sen Sok Valley Campus**

Address: #29, Street 1946, Sangkat Phnom Penh Thmey, Khan Sen Sok, Phnom Penh, Cambodia.

VP.Start

www.vpstart.com